# សេចក្ដីថ្លែងការណ៍រួម
# រវាង
# រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
# និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
# រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១៩

១. តបតាមការអញ្ជើញរបស់**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្ដម ថងលុន ស៊ីសុលីត** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានអញ្ជើញមកបំពេញទស្សនកិច្ចផ្លូវការនៅព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី១២-១៣ ខែកញ្ញា ឆ្នាំ២០១៩។ **ឯកឧត្ដម ថងលុន ស៊ីសុលីត** ព្រមទាំងគណប្រតិភូអមដំណើរ ដែលរួមមាន **ឯកឧត្ដម សាលើមសៃ គុំម៉ាស៊ីត** រដ្ឋមន្ត្រីការបរទេសឡាវ និងមន្ត្រីជាន់ខ្ពស់ដទៃទៀត ត្រូវបានទទួលស្វាគមន៍យ៉ាងរាក់ទាក់កក់ក្ដៅពីរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។

២. ក្នុងឱកាសទស្សនកិច្ចនេះ **ឯកឧត្ដម ថងលុន ស៊ីសុលីត** បានអញ្ជើញដាក់កំរងផ្កានៅវិមានឯករាជ្យ ដើម្បីគោរពវិញ្ញាណក្ខន្ធដល់វីរបុរស និងវីរនារីកម្ពុជា ដែលបានពលីជីវិតនៅក្នុងសង្គ្រាម និងបានអញ្ជើញគោរពវិញ្ញាណក្ខន្ធនៅមណ្ឌប**សម្ដេចព្រះបាទនរោត្ដមសីហនុ ព្រះបរមរតនៈកោដ្ឋ** អតីតព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។ **ឯកឧត្ដមនាយករដ្ឋមន្ត្រីឡាវ** បានអញ្ជើញចូលជួបសម្ដែងការគួរសមជាមួយ **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និងជាប្រមុខរដ្ឋស្ដីទី និង **សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ដោយក្នុងឱកាសនោះ **ឯកឧត្ដមនាយករដ្ឋមន្ត្រីឡាវ** បានធ្វើការផ្លាស់ប្ដូរយោបល់យ៉ាងស្និទ្ធស្នាលជាមួយថ្នាក់ដឹកនាំកម្ពុជា ឆ្លុះបញ្ចាំងពីទំនាក់ទំនងមិត្តភាពជិតស្និទ្ធ និងយូរអង្វែងរវាងប្រទេសទាំងពីរ។

៣. **សម្ដេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** និង **ឯកឧត្ដមនាយករដ្ឋមន្ត្រី ថងលុន ស៊ីសុលីត** បានពិភាក្សាគ្នាដោយត្រង់ៗ ក្នុងបរិយាកាសកក់ក្ដៅ និងយោគយល់គ្នា អំពីបញ្ហាជាច្រើន ដែលជាផលប្រយោជន៍រួមនៃប្រទេសទាំងពីរ។ នាយករដ្ឋមន្ត្រីទាំងពីរបានព្រមព្រៀងគ្នាដូចមាននៅក្នុងចំណុចជាបន្តបន្ទាប់ខាងក្រោម។

៤. ភាគីទាំងពីរបានឯកភាពគ្នាលើកកម្ពស់ទំនាក់ទំនងរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវដល់កំរិតជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងយូរអង្វែង ក្នុងគោលបំណងពង្រឹង និងពង្រីកចំណងមិត្តភាព ស្មារតីសាមគ្គីភាពជាភាតរៈ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ក្នុងវិស័យនយោបាយ-សន្តិសុខ សេដ្ឋកិច្ច និងសង្គម-វប្បធម៌។ ភាគីទាំងពីរនឹងបន្តអភិវឌ្ឍន៍ទំនាក់ទំនងមិត្តភាព ដោយឈរលើមូលដ្ឋានច្បាប់អន្តរជាតិ ជាពិសេសគោលការណ៍ដែលមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន។ ភាគីទាំងពីរបានបញ្ជាក់ជាថ្មីពីការទុកចិត្ត និងការជឿជាក់គ្នាទៅវិញទៅមក និងការគោរពគោលការណ៍មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងរបស់គ្នាទៅវិញទៅមក ការមិនប្រើប្រាស់កម្លាំង ឬការគម្រាមប្រើកម្លាំង ការដោះស្រាយទំនាស់ដោយ

សន្តិវិធី ព្រមទាំងមិនអនុញ្ញាតឱ្យក្រុមអ្នកនយោបាយ ឬកម្លាំងប្រដាប់អាវុធបរទេសណាមួយប្រើប្រាស់ទឹកដីរបស់ខ្លួន ដើម្បីប្រឆាំងនឹងភាគីម្ខាងទៀតឡើយ។

៥. ភាគីទាំងពីរនឹងបន្តរក្សាការជួបប្រជុំកំរិតខ្ពស់ឱ្យបានទៀងទាត់ រវាងតំណាងរដ្ឋាភិបាល និងស្ថាប័នរដ្ឋផ្សេងទៀតរបស់ប្រទេសទាំងពីរ ដើម្បីពង្រឹង និងពង្រីកកិច្ចសម្របសម្រួល និងរួមគ្នាដោះស្រាយបញ្ហានានាឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព សំដៅលើកកម្ពស់ការជឿទុកចិត្តគ្នារវាងប្រជាជាតិទាំងពីរ។

៦. ភាគីទាំងពីរបានឯកភាពគ្នា ប្រគល់ភារកិច្ចជូនគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែននៃប្រទេសទាំងពីរ ដើម្បីរួមគ្នាព្រាងឱ្យបានឆាប់បំផុតនូវ **សន្ធិសញ្ញាស្តីពីការខណ្ឌសីមាព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា** និង **សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ** ពាក់ព័ន្ធកំណាត់ព្រំដែនដែលភាគីទាំងពីរបានកំណត់ខណ្ឌសីមារួចរាល់ហើយចំនួន៨៦%នៃខ្សែព្រំដែនរវាងប្រទេសទាំងពីរ។ ចំពោះកំណាត់ព្រំដែនដែលនៅសេសសល់មិនទាន់ខណ្ឌសីមា ភាគីទាំងពីរបានព្រមព្រៀងគ្នាថានឹងបន្តពិភាក្សារិះរកផ្លូវដោះស្រាយបញ្ហាដោយសន្តិវិធីឱ្យបានឆាប់បំផុត។ ភាគីទាំងពីរក៏បានឯកភាពប្រគល់ភារកិច្ចជូនគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែននៃប្រទេសទាំងពីរ ឱ្យពិភាក្សាគ្នាអំពីការដាំបង្គោលព្រំដែនបន្ថែមនៅលើកំណាត់ព្រំដែនចំនួន៨៦% និងផលិតផែនទីព្រំដែនដោយបង្ហាញពីខ្សែព្រំដែនដែលភាគីទាំងពីរបានទទួលយកសម្រាប់ភ្ជាប់ជាឧបសម្ព័ន្ធនៃសន្ធិសញ្ញាដូចពោលខាងលើ។

៧. លើសពីនេះទៀត ភាគីទាំងពីរបានឯកភាពគ្នាលើកទឹកចិត្តដល់អាជ្ញាធរពាក់ព័ន្ធនៃប្រទេសទាំងពីរ ទាំងថ្នាក់ជាតិ និងថ្នាក់តំបន់ ឱ្យអនុវត្តនូវតួនាទីប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ដើម្បីធានានូវសន្តិភាព និងស្ថិរភាពនៅតាមបណ្តោយព្រំដែននៃប្រទេសទាំងពីរ និងដើម្បីធ្វើឱ្យព្រំដែនកម្ពុជា-ឡាវក្លាយជាព្រំដែនសន្តិភាព មិត្តភាព និងកិច្ចសហប្រតិបត្តិការជានិរន្តរ៍។

៨. ភាគីទាំងពីរបានព្រមព្រៀងគ្នា ធ្វើការសម្របសម្រួល និងសហការគ្នាយ៉ាងជិតស្និទ្ធក្នុងវិស័យការពារជាតិ និងសន្តិសុខសាធារណៈ ជាពិសេសតាមរយៈការពិគ្រោះយោបល់ជាទៀងទាត់ និងការផ្លាស់ប្តូរទស្សនកិច្ចគ្រប់ជាន់ថ្នាក់ កម្មវិធីផ្លាស់ប្តូរនិស្សិត កិច្ចសហប្រតិបត្តិការកុងស៊ុល និងច្បាប់ រួមទាំងក្នុងការងារផ្ទេរទណ្ឌិត និងកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀនខុសច្បាប់ ព្រមទាំងបទល្មើសឆ្លងដែនដទៃទៀត ដោះស្រាយបញ្ហាឆ្លងដែនដែលមានដូចជា ជំងឺឆ្លង និងគ្រោះមហន្តរាយផ្សេងៗ។

៩. ភាគីទាំងពីរបានបញ្ជាក់សារជាថ្មីអំពីសារៈសំខាន់នៃការបង្កើនទំនាក់ទំនងសេដ្ឋកិច្ចទ្វេភាគីតាមរយៈកិច្ចប្រឹងប្រែងរួមដើម្បីបង្កើនការផ្លាស់ប្តូរពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ ហើយព្រមទាំងជំរុញកិច្ចសហប្រតិបត្តិការលើវិស័យផ្សេងៗទៀតដូចជា វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហិរញ្ញវត្ថុ ការដឹកជញ្ជូន ទូរគមនាគមន៍ ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជលូតុវិទ្យា និងបរិស្ថាន។ ភាគីទាំងពីរយល់ស្របគ្នាថា ការពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកសង្គម-វប្បធម៌ ដែលរួមមានសុខុមាលភាពសង្គម អប់រំ និងកីឡា ព័ត៌មាន វប្បធម៌ និងទេសចរណ៍ ការថែរក្សាសុខភាព និង

យុវជន មិនត្រឹមតែជួយគាំទ្រដល់ទំនាក់ទំនងវិស័យសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកកម្ពស់ស្មារតីមិត្តភាពរវាងប្រជាជាតិទាំងពីរផងដែរ។

១០. ភាគីទាំងពីរបានឯកភាពគ្នាជំរុញកិច្ចសហប្រតិបត្តិការលើវិស័យថាមពល ជាពិសេសតាមរយៈការបង្កើនពាណិជ្ជកម្មទ្វេភាគីផ្នែកថាមពលអគ្គិសនី ផលិតពីប្រភពវារីអគ្គិសនី រោងចក្រដើរដោយធ្យូងថ្ម និងប្រភពថាមពលកកើតឡើងវិញផ្សេងៗទៀត រវាងប្រទេសទាំងពីរនៅក្នុងបណ្តាឆ្នាំខាងមុខ ផ្អែកតាមសមត្ថភាពផងខ្លួន។ ក្នុងន័យនេះ ភាគីទាំងពីរបានឯកភាពគ្នាជំរុញលើកទឹកចិត្តដល់ស្ថាប័នពាក់ព័ន្ធទាំងសងខាង ធានាថាការសាងសង់បណ្តាញបញ្ជូនអគ្គិសនីតង់ស្យុងខ្ពស់ រវាងកម្ពុជា និងឡាវនឹងត្រូវបានរួចរាល់តាមការព្រមព្រៀងគ្នា និងស្របតាមផែនការ។ ភាគីទាំងពីរបានបង្ហាញនូវបំណងរួមក្នុងការជំរុញពាណិជ្ជកម្មថាមពលថ្នាក់តំបន់ ហើយយល់ស្របគ្នាថាពាណិជ្ជកម្មថាមពលរវាងកម្ពុជា ឡាវ និងវៀតណាម អាចនឹងជំរុញបានតាមរយៈការបង្កើតនូវបណ្តាញបញ្ជូនអគ្គិសនីរួមនៃប្រទេសទាំងបី។

១១. ភាគីទាំងពីរបានឯកភាពគ្នាជំរុញកិច្ចសហប្រតិបត្តិការទីក្រុងសម្ព័ន្ធមេត្រី រវាងរាជធានីភ្នំពេញ និងវៀងចន្ទ និងរវាងខេត្តសៀមរាប និងខេត្តចំប៉ាសាក់ ។ លើសពីនេះទៀត ភាគីទាំងពីរបានឯកភាពជំរុញមន្ត្រីរៀងៗខ្លួន នៅតាមបណ្តាខេត្តជាប់ព្រំដែនឱ្យធ្វើការជួបប្រជុំ និងពិគ្រោះយោបល់គ្នាជាប្រចាំ ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការ និងជួយគ្នាទៅវិញទៅមក លើគ្រប់វិស័យ ដែលបម្រើផលប្រយោជន៍ទៅវិញទៅមក។

១២. ភាគីទាំងពីរបានឯកភាពបន្តបង្កើនកិច្ចសហប្រតិបត្តិការនៅក្នុងក្របខ័ណ្ឌអនុតំបន់ និងយន្តការតំបន់ ដើម្បីការអភិវឌ្ឍសេដ្ឋកិច្ចតំបន់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងប្រកបដោយចីរភាពតាមរយៈការអនុវត្តនូវកិច្ចព្រមព្រៀងដែលមានស្រាប់ ពិសេសនៅក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការតំបន់អភិវឌ្ឍត្រីកោណកម្ពុជា-ឡាវ-វៀតណាម៕

ថ្ងៃ ព្រហស្បតិ៍ ១៤កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៩